**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ: ១៤៧ ជនស/អគសណ

ថ្ងៃចន្ទ ៣កើត ខែ ចេត្រ ឆ្នាំម្សាញ់សប្តស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២៥

**សូមជម្រាបមក**

**លោក សឿម សាអ៊ីម**

**កម្មវត្ថុ** : សំណើសុំរុះរើអគារសណ្ឋាគារ និងកាស៊ីណូ ចំនួន ០១ អគារ មានកម្ពស់ ១៧ជាន់ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០១១០០៤០៧-០២៥៤ ដែលមានទីតាំងស្ថិតនៅភូមិប៉ោយប៉ែត សង្កាត់អូរជ្រៅ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

**យោង** :
- ព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០១៩ ប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- អនុក្រឹត្យលេខ ២២៤ អនក្រ.បក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់
- ប្រកាសលេខ ០៤៧ ជនស/ប្រ.ក/នី.ក ចុះថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ ២០២២ ស្តីពីកម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់
- ពាក្យស្នើសុំលិខិតអនុញ្ញាតរុះរើ ចុះថ្ងៃទី ២៣ ខែមករា ឆ្នាំ២០២៥ របស់ឈ្មោះ សឿម សាអ៊ីម
- របាយការណ៍សង្ខេបលេខ ០៤១ ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០២៥ ស្តីពីការពិនិត្យ និងវាយតម្លៃគម្រោងស្នើសុំលិខិតអនុញ្ញាតរុះរើ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមជម្រាបលោកថា ផ្អែកតាមការត្រួតពិនិត្យ និងវាយតម្លៃរបស់មន្ត្រីជំនាញ នៃនាយកដ្ឋានសំណង់បានឃើញថា អគារសណ្ឋាគារ និងកាស៊ីណូ ចំនួន ០១ អគារ មានកម្ពស់ ១៧ជាន់ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលវត្ថុលេខ ០១១០០៤០៧-០២៥៤ ស្ថិតនៅភូមិប៉ោយប៉ែត និងភូមិប៉ោយប៉ែត សង្កាត់អូរជ្រៅ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ របស់ក្រុមហ៊ុន ដាយអឹមិនស៊ីធីប្រាយវេតលីមីធីតខមភេនី តំណាងដោយលោក សឿម សាអ៊ីម ត្រូវបានរងអគ្គិភ័យឆាបឆេះផ្នែកចំហៀង បណ្តាលឱ្យមិនអាចប្រើប្រាស់បាន។ ដូច្នេះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុញ្ញាតឱ្យលោកធ្វើការរុះរើតាមការស្នើសុំ ដោយត្រូវគោរពតាមលក្ខខណ្ឌខាងក្រោម÷

- រៀបចំធ្វើរនាំងបាំងការពារកម្ទេចសម្ភារៈសំណង់ និងផង់ធូលីកុំឱ្យប៉ះពាល់ដល់អ្នកជិតខាង
- ថែរក្សាការពារសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈឱ្យបានល្អ
- អនុវត្តឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស

- ករណីមានហានិភ័យដោយប្រការណាមួយ លោកត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

អាស្រ័យហេតុនេះ សូម **លោក** ជ្រាប និងចាត់ចែងតាមការគួរ។

សូម **លោក** ទទួលនូវការរាប់អានពីខ្ញុំ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការប្រចាំការ

**តឹករ៉ែត សំរេច**

**ចម្លងជូន** :

- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អគ្គនាយកដ្ឋាននៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋបាលខេត្តបន្ទាយមានជ័យ
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តបន្ទាយមានជ័យ
- ឯកសារ-កាលប្បវត្តិ